**VIRGINIA DEPARTMENT OF LABOR AND INDUSTRY (DOLI)**

**កម្មវិធីសុវត្ថិភាព និងសុខភាពមុខរបររបស់រដ្ឋ VIRGINIA (VIRGINIA OCCUPATIONAL SAFETY AND HEALTH (VOSH) PROGRAM)**

**ស្តង់ដារបណ្តោះអាសន្នពេលមានគ្រោះអាសន្នរបស់កម្មវិធី VOSH សម្រាប់ជំងឺរាតត្បាត COVID-19**

## *ការណែនាំសម្រាប់និយោជក និងបុគ្គលិក*

ខណៈពេលកំពុងជួបប្រទះនូវផលប៉ះពាល់ដ៏ធ្ងន់ធ្ងរនៃជំងឺរាតត្បាត COVID-19 គណៈកម្មការនៃក្រមស្តីពីសុវត្ថិភាព និងសុខភាពរដ្ឋ Virginia (Virginia Safety and Health Codes Board) បានអនុម័តនូវ **ស្តង់ដារបណ្តោះអាសន្នពេលមានគ្រោះអាសន្ន គឺការបង្ការជំងឺឆ្លងៈ វីរុស SARS-CoV-2 ដែលបង្កជាជំងឺ COVID-19 16VAC25-220** ដើម្បីការពារបុគ្គលិក និងនិយោជកពីការឆ្លងរាលដាលនៃជំងឺ COVID-19។ ស្តង់ដារថ្មីនេះនឹងរក្សាសុវត្ថិភាព និងសុខភាពនៅកន្លែងធ្វើការរបស់ប្រជាជននៅរដ្ឋ Virginia ទំនុកចិត្តរបស់អតិថិជនលើសុវត្ថិភាពរបស់គ្រឹះស្ថានអាជីវកម្មនៅក្នុងរដ្ឋ Virginia និងអាចឲ្យនិយោជកបើកដំណើរការអាជីវកម្មបាន។

---

## ព័ត៌មានសំខាន់

ព័ត៌មានថ្មីបំផុតស្តីពីស្តង់ដារបណ្តោះអាសន្នពេលមានគ្រោះអាសន្ន (ETS) អាចរកបាននៅ www.doli.virginia.gov. សម្ភារៈសម្រាប់ការផ្សព្វផ្សាយ ការអប់រំ និងការបណ្តុះបណ្តាលនឹងអាចរកបាននៅ ឬមុនថ្ងៃទី27 ខែកក្កដា ឆ្នាំ2020។

ETS នឹងមានសុពលភាពភ្លាមៗបន្ទាប់ពីការបោះពុម្ពផ្សាយ ដែលរំពឹងថានឹងធ្វើឡើងនៅក្នុងអំឡុងសប្តាហ៍នៃថ្ងៃទី27 ខែកក្កដា ឆ្នាំ2020។ ETS អនុវត្តសម្រាប់និយោជក និងបុគ្គលិកឯកជន រដ្ឋ និងរដ្ឋាភិបាលក្នុងតំបន់ទាំងអស់ដែលគ្របដណ្តប់ដោយដែនយុត្តាធិការរបស់ VOSH។ ETS នឹងអស់សុពលភាពក្រោយរយៈពេលប្រាំមួយខែបន្ទាប់ពីកាលបរិច្ឆេទមានសុពលភាព ប៉ុន្តែគណៈកម្មការនៃក្រមស្តីពីសុវត្ថិភាព និងសុខភាព នឹងពិចារណាក្នុងការអនុម័តស្តង់ដារជំនួសជាអចិន្ត្រៃយ៍ក្នុងអំឡុងពេលជាមួយគ្នានោះផងដែរ។

កម្មវិធី VOSH នឹងធ្វើការត្រួតពិនិត្យអនុលោមភាពក្រោម ETS។ ដើម្បីយល់ដឹងឲ្យបានកាន់តែប្រសើរ និងអនុវត្តដោយស្ម័គ្រចិត្តតាម ETS សូមទាក់ទងទៅកាន់ DOLI ដើម្បីស្នើសុំសេវាកម្មពិគ្រោះយោបល់ និងបណ្តុះបណ្តាល**ដោយឥតគិតថ្លៃ និងសម្ងាត់**។

---

## ប្រាំបួនជំហានដើម្បីសម្រេចឲ្យបានអនុលោមភាព

**ជំហានទី 1៖** ចូលកន្លែងធ្វើការរបស់អ្នកដើម្បីរកមើលថាមានគ្រោះថ្នាក់ ឬកិច្ចការងារដែលអាចបណ្តាលឲ្យបុគ្គលិកប្រឈមនឹងការឆ្លងវីរុស SARS-CoV-2 ឬជំងឺ COVID-19 ដែរឬទេ។ និយោជកត្រូវចាត់ប្រភេទកិច្ចការងារឲ្យស្របទៅតាមគ្រោះថ្នាក់ដែលបុគ្គលិកកំពុងប្រឈម និងធានាអនុលោមភាពតាមផ្នែកជាធរមាននៃ ETS សម្រាប់

កម្រិតហានិភ័យនៃការប្រឈម "ខ្ពស់ខ្លាំង", "ខ្ពស់", "មធ្យម" ឬ "ទាប"។ កិច្ចការដែលមានលក្ខណៈស្រដៀងគ្នា និង បណ្តាលឲ្យបុគ្គលិកប្រឈមនឹងគ្រោះថ្នាក់ដូចគ្នា អាចត្រូវបានគេចាត់ជាក្រុមសម្រាប់គោលបំណងចាត់ជាប្រភេទ។

- **ហានិភ័យទាប៖** ការងារដែលមានហានិភ័យទាបគឺជាការងារដែលមិនតម្រូវឲ្យមានការប៉ះពាល់ក្នុងចម្ងាយប្រាំមួយហ្វីតជាមួយនឹងបុគ្គលដែលត្រូវបានគេដឹងថា សង្ស័យថា ឬអាចត្រូវបានឆ្លងវីរុស SARS-CoV-2។ បុគ្គលទាំងនេះមានការប៉ះពាល់ក្នុងការងារក្នុងកម្រិតអប្បបរមាជាមួយបុគ្គលិកដទៃទៀត ឬសាធារណជនទូទៅ ឬអាចមានការប៉ះពាល់ក្នុងការងារក្នុងកម្រិតអប្បបរមាតាមរយៈការអនុវត្តការគ្រប់គ្រងការបំពេញការងារ។

- **ហានិភ័យមធ្យម៖** ការងារដែលមានហានិភ័យមធ្យមគឺជាការងារដែលតម្រូវឲ្យមានការប៉ះពាល់ក្នុងការងារលើសពីកម្រិតអប្បបរមា ការប៉ះពាល់ក្នុងចម្ងាយប្រាំមួយហ្វីតជាមួយនឹងបុគ្គលិកដទៃទៀត ឬបុគ្គលដែលអាចនឹង ប៉ុន្តែមិនត្រូវបានគេដឹងថា ឬសង្ស័យថា បានឆ្លងវីរុស SARS-CoV-2។ អ្នកទាំងនេះអាចនឹងរួមមានជាអាទិ៍ អ្នករត់តុ អ្នកធ្វើការនៅក្នុងហាងលក់ទំនិញ អ្នកធ្វើការក្នុងវិស័យកសិកម្ម កម្មករសំណង់ អ្នកធ្វើការផ្តល់សេវាកម្មតាមផ្ទះ ជាងកាត់សក់ គ្រូបង្ហាត់លំហាត់ប្រាណ អ្នកធ្វើការនៅកន្លែងកែច្នៃសាច់ និងបសុបក្សី កម្មករផ្នែកផលិតកម្ម និងបុគ្គលិកផ្នែកថែទាំវេជ្ជសាស្ត្រ នៅក្នុងបរិយាកាសនៃប្រភពដែលមិនត្រូវបានគេដឹង ឬសង្ស័យថាមាន SARS-CoV-2។
- **ហានិភ័យខ្ពស់៖** ការងារដែលមានហានិភ័យខ្ពស់គឺជាការងារទាំងឡាយណាដែលមានការប្រឈមខ្ពស់ដល់បុគ្គលិកក្នុងចម្ងាយប្រាំមួយហ្វីតជាមួយនឹងប្រភពដែលត្រូវបានគេដឹង ឬសង្ស័យថាមានវីរុស SARS-CoV-2។ បុគ្គលិកទាំងនេះរួមមានបុគ្គលិកមន្ទីរពេទ្យ បុគ្គលិកជួរមុខ អ្នកផ្តល់ការដឹកជញ្ជូនក្នុងវិស័យវេជ្ជសាស្ត្រ បុគ្គលិកផ្នែកសេវាកម្មតម្កល់សាកសព បុគ្គលិកវេជ្ជសាស្ត្រ និងទន្តសាស្ត្រ បុគ្គលិកជំនួយមិនមែនវេជ្ជសាស្ត្រ បុគ្គលិកថែទាំអគារសុខភាពរយៈពេលវែង បុគ្គលិកថែទាំវេជ្ជសាស្ត្រតាមផ្ទះ។ល។

- **ហានិភ័យខ្ពស់ខ្លាំង៖** ការងារដែលមានហានិភ័យខ្ពស់ខ្លាំងគឺជាការងារទាំងឡាយណាដែលមានការប្រឈមខ្ពស់ដល់បុគ្គលិកក្នុងចម្ងាយប្រាំមួយហ្វីតជាមួយនឹងប្រភពដែលត្រូវបានគេដឹង ឬសង្ស័យថាមានវីរុស SARS-CoV-2 ក្នុងអំឡុងពេលអនុវត្តដំណើរការវេជ្ជសាស្ត្រ (ឧទាហរណ៍៖ aerosol generating procedures) ដំណើរការកោសល្យវិច្ច័យសាកសព (postmortem) ឬដំណើរការនៅមន្ទីរពិសោធន៍ជាក់លាក់ជាមួយនឹងសំណាកពីប្រភពដែលត្រូវបានគេដឹង ឬសង្ស័យថាមានវីរុស SARS-CoV-2។

**ជំហានទី 2៖** បង្កើត និងអនុវត្តប្រព័ន្ធមួយសម្រាប់ការវាយតម្លៃដោយខ្លួនឯង និងការធ្វើតេស្តរកសញ្ញា និងរោគសញ្ញានៃជំងឺ COVID-19 របស់បុគ្គលិក (សូមមើលលក្ខខណ្ឌតម្រូវជាក់លាក់តាមចំណាត់ប្រភេទនៃហានិភ័យ)។

**ជំហានទី 3៖** ផ្តល់ជូនគោលការណ៍ច្បាប់ឈប់សម្រាកពេលមានជំងឺដែលអាចបត់បែនបាន ការធ្វើការងារពីផ្ទះ វេនការងារដែលត្រូវបានកំណត់ និងការគ្រប់គ្រងការអនុវត្តផ្នែករដ្ឋបាល/ការងារផ្សេងៗទៀត នៅពេលដែលអាចអនុវត្តបាន ដើម្បីកាត់បន្ថយ ឬលុបបំបាត់ការប៉ះពាល់ជាមួយអ្នកដទៃក្នុងចម្ងាយប្រាំមួយហ្វីត។ លើកទឹកចិត្តបុគ្គលិកឲ្យរាយការណ៍អំពីរោគសញ្ញាដោយធានាថាពួកគេយល់ដឹងអំពីគោលការណ៍ច្បាប់ឈប់សម្រាកពេលមានជំងឺ និងការចាត់ចែងការងារដែលមានជម្រើស ក៏ដូចជាច្បាប់ឈប់សម្រាកពេលមានជំងឺដោយមានប្រាក់ឈ្នួលដែលមានតាមរយៈច្បាប់ស្តីពីការឆ្លើយតបនឹងវីរុសកូរ៉ូណាជំបូងដោយគ្រួសារ (Families First Coronavirus Response Act (FFCRA))។

**ជំហានទី 4៖** បង្កើត និងអនុវត្តនីតិវិធីដែលនឹងបង្ការបុគ្គលិក និងបុគ្គលដទៃទៀតដែលឈឺពីការចម្លងជំងឺទៅកាន់បុគ្គលិកដែលមានសុខភាពល្អ៖

1. អនុវត្តការគ្រប់គ្រងផ្នែកវិស្វកម្ម ឬការអនុវត្តការងារ ដែលលុបបំបាត់ ឬកាត់បន្ថយគួរឲ្យកត់សម្គាល់នូវការប្រឈមរបស់បុគ្គលិកទៅនឹងវីរុស SARS-CoV-2។
2. ធានាថាបុគ្គលិកអនុវត្តការរក្សាគម្លាតរាងកាយ ខណៈពេលបំពេញការងារ និងអំឡុងពេលការឈប់សម្រាកដែលទទួលបានប្រាក់ឈ្នួល។
3. តម្រូវឲ្យបុគ្គលិកគោរពតាមការអនុវត្តផ្នែកសុវត្ថិភាព និងសុខភាពដែលមានគូសបញ្ជាក់នៅក្នុង ETS ពាក់ព័ន្ធនឹងឧបករណ៍ការពារ ការរក្សាអនាម័យ ការសម្លាប់មេរោគ និងការលាងដៃ។
4. ផ្តល់ជូនឧបករណ៍ការពារផ្ទាល់ខ្លួនដល់បុគ្គលិក និងធានាឲ្យបាននូវការប្រើប្រាស់ត្រឹមត្រូវនៅពេលដែលការគ្រប់គ្រងផ្សេងទៀតនៅកន្លែងធ្វើការដូចជាការគ្រប់គ្រងផ្នែកវិស្វកម្ម ការផ្លាស់ប្តូរការអនុវត្តការងារ និងការរក្សាគម្លាតសង្គមមិនបានផ្តល់នូវការការពារគ្រប់គ្រាន់។

**ជំហានទី 5៖** បង្កើត និងអនុវត្តនីតិវិធីដើម្បីធានាថាបុគ្គលិកដែលត្រូវបានគេដឹង ឬសង្ស័យថាមានជំងឺ COVID-19 មិនមកធ្វើការ ក៏ដូចជានីតិវិធីសម្រាប់ពួកគេក្នុងការត្រឡប់មកធ្វើការវិញ។ គោលការណ៍ក្នុងការត្រឡប់មកធ្វើការវិញនេះត្រូវរួមបញ្ចូល៖

1. ការហាមឃាត់បុគ្គលិកដែលត្រូវបានគេដឹង ឬសង្ស័យថាមានជំងឺ COVID-19 ពីការត្រឡប់មកធ្វើការវិញ រហូតដល់ពួកគេត្រូវបានអនុញ្ញាតឲ្យត្រឡប់មកធ្វើការ តាមរយៈយុទ្ធសាស្ត្រដែលផ្អែកលើរោគសញ្ញា ឬដោយផ្អែកលើការធ្វើតេស្ត។
2. ប្រសិនបើយុទ្ធសាស្ត្រដោយផ្អែកលើការធ្វើតេស្តមិនត្រូវបានប្រើប្រាស់ គឺត្រូវធ្វើការពិគ្រោះយោបល់ជាមួយអ្នកវិជ្ជាជីវៈផ្នែកថែទាំសុខភាពសមស្របពាក់ព័ន្ធនឹងពេលដែលរោគសញ្ញារបស់បុគ្គលិកបង្ហាញថាវាមានសុវត្ថិភាពសម្រាប់ពួកគេក្នុងការត្រឡប់មកធ្វើការវិញ។

**ជំហានទី 6៖** បង្កើត និងអនុវត្តប្រព័ន្ធសម្រាប់ជូនដំណឹងដល់បុគ្គលិក ម្ចាស់អគារ និងនិយោជកផ្សេងទៀតអំពីការប្រឈមនៅកន្លែងធ្វើការទៅនឹងវីរុស និងករណីសង្ស័យ ឬត្រូវបានបញ្ជាក់ ដើម្បីឲ្យពួកគេអាចចាត់វិធានការផ្ទាល់ខ្លួនដើម្បីការពារសុខភាព និងសុវត្ថិភាពរបស់ពួកគេ។

**ជំហានទី 7៖** ធានាថាអ្នកអនុលោមតាមបទប្បញ្ញត្តិស្តីពីការប្រឆាំងការរើសអើងនៅក្នុង ETS ថ្មី។ នេះរួមមានការជៀសវាងពីការបញ្ឈប់បុគ្គលិក ឬក៏រើសអើសចំពោះបុគ្គលិកតាមរូបភាពណាមួយដោយសារតែពួកគេបានលើកឡើងពីក្តីបារម្ភសមហេតុផលស្តីពីការគ្រប់គ្រងការឆ្លងជំងឺពាក់ព័ន្ធនឹងវីរុស SARS-CoV-2 ឬជំងឺ COVID-19 នៅកន្លែងធ្វើការជាមួយអ្នក បុគ្គលិកផ្សេងទៀតភ្នាក់ងាររដ្ឋាភិបាល ឬក៏ទៅកាន់សាធារណជនតាមរយៈទម្រង់ប្រព័ន្ធផ្សព្វផ្សាយណាមួយ។

**ជំហានទី 8៖** ប្រសិនបើអ្នកជានិយោជកដែលមានបុគ្គលិកចំនួនដប់មួយអ្នក ឬលើសពីនេះ និងការងារនានាដែលត្រូវបានចាត់ទុកជាប្រភេទដែលមានហានិភ័យមធ្យម ឬក៏ជានិយោជកដែលមានបុគ្គលិកក្នុងចំនួនណាមួយ និងការងារនានាដែលត្រូវបានចាត់ទុកជាប្រភេទដែលមានហានិភ័យខ្ពស់ ឬខ្ពស់ខ្លាំង អ្នកត្រូវតែរៀបចំផែនការត្រៀមខ្លួន និងឆ្លើយតបចំពោះជំងឺឆ្លង និងធ្វើការបណ្តុះបណ្តាលបុគ្គលិកស្តីពីការអនុវត្តក្នុងអំឡុងពេល 60ថ្ងៃ ចាប់ពីកាលបរិច្ឆេទមានប្រសិទ្ធភាពនៃ ETS។

**ជំហានទី 9៖** និយោជកដែលមានកន្លែងធ្វើការដែលមានហានិភ័យមធ្យម ខ្ពស់ និងខ្ពស់ខ្លាំង ត្រូវតែផ្តល់ការបណ្តុះបណ្តាលស្តីពីជំងឺ COVID-19 ដល់បុគ្គលិកក្នុងរយៈពេល 30ថ្ងៃ ចាប់ពីកាលបរិច្ឆេទមានសុពលភាព។ កន្លែងការងារដែលមានហានិភ័យទាបត្រូវផ្តល់ជូនបុគ្គលិកនូវព័ត៌មានបឋមជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ស្តីពីគ្រោះថ្នាក់នៃជំងឺ COVID-19 និងវិធានការណ៍ក្នុងការកាត់បន្ថយការប្រឈមនឹងការឆ្លង។ ផ្ទាំងផ្សព្វផ្សាយនៅកន្លែងធ្វើការដែលអាចទទួលយកបាន នឹងអាចរកបានដោយឥតគិតថ្លៃដោយ VOSH តាមរយៈ www.doli.virginia.gov។

សូមប្រឹក្សាយោបល់អំពី ETS ជាក់ស្តែង ក៏ដូចជាសម្ភារៈសម្រាប់ការផ្សព្វផ្សាយ ការអប់រំ និងការបណ្តុះបណ្តាលដែលអាចរកបាននៅ www.doli.virginia.gov។